00815281

E176/2/1/1

# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (...)

ភាគីដាក់ឯកសារ: ក្រុមមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 14 / 06 / 2012
ម៉ោង (Time/Heure): 13:55
Case File Officer/L'agent chargé: SANN RADA

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ: សាធារណៈ / Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# បណ្តឹងសាទុក្ខឆ្លាមៗប្រឆាំងនឹង សេចក្តីសម្រេចលើសំណើសុំឲ្យមាន ចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តីលោក នួន ជា៖**

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
Scarlet WAGNER
Devika KAMP

**ចម្លងជូន៖**

**សហព្រះរាជអាជ្ញា៖**

ជា លាង
Andrew CAYLEY

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ
Elisabeth SIMONNEAU-FORT

## I. សេចក្ដីផ្ដើម

១. អនុលោមតាមវិធាន ៣៥, ១០៤, ១០៥ និង ១០៧ នៃវិធានផ្ទៃក្នុង អ.វ.ត.ក[1] ("វិធាន") មេធាវីការពារក្ដីជនជាប់ចោទ នួន ជា ("មេធាវីការពារក្ដី") សូមដាក់បណ្ដឹងសាទុក្ខភ្លាមៗនេះប្រឆាំងនឹង "សេចក្ដីសម្រេចលើសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥" ("សេចក្ដីសម្រេចដែលត្រូវបានជំទាស់")[២]។ ដោយមានសំអាងហេតុដែលនឹងលើកឡើងនៅខាងក្រោមនេះ មេធាវីការពារក្ដីសូមសន្និដ្ឋានថា៖ (១) បណ្ដឹងសាទុក្ខនេះអាចទទួលយកបាន (២) សេចក្ដីសម្រេចដែលត្រូវបានជំទាស់មិនអាចការពារតាមផ្លូវច្បាប់ ដោយសារមានសំអាងហេតុមួយចំនួន និង (៣) អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") អាច និងត្រូវតែអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីជួសជុលកំហុសដោយអង្គជំនុំជម្រះសាលាដំបូង។ ជាបញ្ហាបឋម មេធាវីការពារក្ដីសូមប្រកាន់ជំហរថា បណ្ដឹងសាទុក្ខភ្លាមៗនេះគួរត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈ។ នៅគ្រប់កាលៈទេសៈទាំងអស់ ឯកសារនេះត្រូវចាត់ទុកថាជាឯកសារសាធារណៈ។

## II. អង្គហេតុដែលពាក់ព័ន្ធ និងប្រវត្តិនីតិវិធី

២. មេធាវីការពារក្ដីសូមយោងទៅដល់សេចក្ដីសន្និដ្ឋានអង្គហេតុនានា (និងសម្ភារៈ/ឯកសារគាំទ្រជាមូលដ្ឋាន) ដែលមាននៅក្នុង "សុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥" (សំណើ)[3]។ ជាការលើកឡើងបញ្ជាក់ឡើងវិញដោយសង្ខេប: "កាលពីថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ មានការរាយការណ៍នៅក្នុងសារព័ត៌មានវៀតណាម ដែលលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការកត់សម្គាល់ដូចខាងក្រោមនៅក្នុងសន្និសីទសារព័ត៌មាន នៅពីរថ្ងៃមុននៅក្នុងខេត្ត Dong Nai ប្រទេសវៀត ណាម៖

---

[1] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៨) វិសោធនកម្មថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១។

[2] ឯកសារលេខ E176/2, ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១២, លេខ ERN៖ 00806873–00806883។

[3] សូមមើលឯកសារ **E-176** ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២, ERN 00782947–00782959 កថាខណ្ឌ ២ ដល់ ៧។

ការអធិប្បាយពីការចោទប្រកាន់ដោយមេដឹកនាំខ្មែរក្រហមនៅឯសវនាការកាត់សេចក្តី កាលពីខែកន្លងទៅថា ប្រទេសវៀតណាមបានឈ្លានពានប្រទេសកម្ពុជានៅទសវត្សទីឆ្នាំ៧០, ហ៊ុន សែន និយាយថាវាមិនចាំបាច់ឆ្លើយតបទៅនឹងពាក្យសំដី "បោកប្រាស់ហ្នឹងទេ" ។

ឃាតករ និងជនដៃដល់នៃអំពើប្រល័យពូជសាសន៍កំពុងតែការពារខ្លួនដែលជាកិច្ចប្រឹងប្រែងមួយដើម្បីធ្វើឲ្យផុតពីឧក្រិដ្ឋកម្ម ។ គេគ្រប់គ្នាដឹងថាប្រទេសរបស់យើងធ្លាប់មានរបបប្រល័យពូជសាសន៍ ហើយឥឡូវនេះយើង និងពិភពលោកកំពុងដំណើរការកាត់ទោសពួកគេ"[4] ។

*គ្មានមន្ទិលសង្ស័យនោះទេ*លោកនាយករដ្ឋមន្ត្រីនិយាយសំដៅលើ នួន ជា ដែលជាមេដឹកនាំខ្មែរក្រហមតែម្នាក់គត់បានផ្តល់សក្ខីកម្មនៅសវនាការនាខែ ធ្នូ ឆ្នាំ ២០១១ អំពីការចូលឈ្លានពានរបស់វៀតណាមមកលើកម្ពុជានាទសវត្សឆ្នាំ១៩៧០។

៣. ក្នុងការឆ្លើយតបនឹងការប៉ុនប៉ងរបស់មេធាវីការពារក្តី ដែលចោទប្រកាន់លើសេចក្តីថ្លែងការណ៍ លោកនាយករដ្ឋមន្ត្រីព្យាយាមនិយាយសម្រួលដល់ផលប៉ះពាល់ដោយសេក្តីថ្លែងការណ៍របស់លោកថា៖

> "ខ្ញុំចង់ធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈអំពីមេធាវីការពារក្តីបងធំទី២ ដែលចង់ប្តឹងខ្ញុំ" ដែលសូមឲ្យមានការឆ្លើយតបពីទីស្តីការគណៈរដ្ឋមន្ត្រី សុខ អាន។ "ខ្ញុំត្រូវបានគេសួរនៅប្រទេសវៀតណាមអំពីឧក្រិដ្ឋកម្មនៅក្នុងសម័យខ្មែរក្រហម ក៏ប៉ុន្តែមេធាវីការពារក្តីរបស់លោក នួន ជា ចោទខ្ញុំអំពីការជ្រៀតជ្រែកក្នុងកិច្ចការតុលាការ។ "សេចក្តីថ្លែងការណ៍របស់ខ្ញុំអំពី ប៉ុល ពត, នួន ជា, ខៀវ សំផន និង អៀង សារី គឺមិនមានឥទ្ធិពលអ្វីលើតុលាការក្នុងពេលនេះទេ"[5] ។

ទោះបីជាយ៉ាងណាក៏ដោយការនិយាយលើកចុងក្រោយរបស់គាត់អំពីបញ្ហានេះថា៖ "តុលាការអាចធ្វើអ្វីតាមដែលខ្លួនចង់ *ក៏ប៉ុន្តែខ្ញុំក៏មានសិទ្ធិជេរមេដឹកនាំខ្មែរក្រហមដែរ"*[6]។

---

[4] Minh Nam, Tan Tu, and An Dien, 'Vietnam did not invade, but revived Cambodia: Hun Sen', *Than Nien News/Vietweek,* 5 January 2012 (reproduced in ECCC Media Clippings: 7–9 January 2012, p 8).

[5] *The Cambodia Herald,* 'Hun Sen calls for government response to accusations by Nuon Chea's lawyer', 18 February 2012).

[6] សំណើកថាខណ្ឌទី ៦ (ដកស្រង់ *The Cambodia Herald*, 'Hun Sen calls for government response to accusations by Nuon Chea's lawyer', 18 February 2012.។ សូមមើលផងដែរ Vong Sokheng & David Boyle, *The Phnom Penh Post,* 'KR leadership fair game: PM', 20 February 2012 (ក្នុងជំនួបប្រជុំបិទទ្វាររបស់រដ្ឋាភិបាលជាមួយជាមួយតំណាងសង្គមស៊ីវិលនៅថ្ងៃ សុក្រ លោក នាយករដ្ឋមន្ត្រីនិយាយថា គាត់មិនត្រូវបានហាមឃាត់មិនឲ្យនិយាយអំពីទោសឧក្រិដ្ឋរបស់ នួន

៤. នៅក្នុងសំណើដែលរួមបញ្ចូល និងធ្វើឡើងនូវបណ្តឹងផ្ទាល់មាត់លើកមុននៅក្នុងបណ្តឹងសរសេរជាលាយលក្ខណ៍អក្សរ (តាមរយៈការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូង)មេធាវីការពារក្តីបានលើកឡើងថា (១) ការកត់សម្គាល់នាពេលថ្មីៗនេះដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅកាន់សារព័ត៌មានវៀតណាមជាការរំលោភសិទ្ធិរបស់ នួន ជា ដែលត្រូវសន្មតជាមុនថាគ្មានទោសនៅក្រោមរដ្ឋធម្មនុញ្ញកម្ពុជា ដែលចាត់ទុកថាការជ្រៀតជ្រែកមកក្នុងការងាររបស់តុលាការនៅ អ.វ.ត.ក[7] និង (២) អង្គជំនុំជម្រះត្រូវតែផ្តល់នូវដំណោះស្រាយដ៏មានប្រសិទ្ធភាព និងមានប្រយោជន៍ចំពោះការរំលោភបែបនេះ[8]។

៥. ក្នុងការបដិសេធសំណើរបស់មេធាវីការពារក្តីអង្គជំនុំជម្រះទទួលស្គាល់ថា ការកត់សម្គាល់របស់ ហ៊ុន សែន ដែល "នឹងអាចដូចជាសំដៅជាពិសេសទៅកាន់លោក នួន ជា"[9] នាំទៅដល់ការរំលោភជាក់ស្តែងមួយទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ: "ដោយមិនគិតថា ការលើកឡើងនោះបានរាយការណ៍ត្រឹមត្រូវឬក៏អត់នោះទេ [...] ការលើកឡើងបែបនេះគឺផ្ទុយទៅនឹងការសន្មតទុកជាមុនថាគ្មានទោស ដែលលោកនួនជា មាននោះ"[10]។ ការប៉ាន់ប្រមាណដល់សេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រីប្រឆាំងនឹងវិធាន ៣៥ "លក្ខខណ្ឌទាបបំផុតសម្រាប់ការស៊ើបអង្កេត"[11] អង្គជំនុំជម្រះសម្រេចដូចខាងក្រោម:

---

ជា នៅក្រោមរបបខ្មែរក្រហមនោះទេ។ "ហាមខ្ញុំមិនឲ្យនិយាយថ្កោលទោស នួន ជា ប៉ុល ពត មានន័យថា ខ្ញុំខុសដែលបានផ្តួលរំលំរបបរបស់របប ប៉ុល ពត" សម្តីគាត់និយាយត្រូវបានថតទុក។ "មើល ទាំងអស់គ្នា ជួយការពារខ្ញុំ ហើយកុំឲ្យមេធាវី នួន ជា ក្លែងក្លាងពេក")។

[7] សំណើ កថាខណ្ឌ ១, ១៧-២០។

[8] សំណើ កថាខណ្ឌ ១, ២១-២៣។

[9] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៥។

[10] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៦។ សូមមើលផងដែរដូចគ្នា កថាខណ្ឌ១៨ (('It is therefore clear from the international jurisprudence that any declaration of an accused person's guilt by a public official prior to a verdict being delivered by a court is incompatible with the presumption of innocence.')

[11] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២០, សូមមើលផងដែរ ("បទដ្ឋាននេះនឹងត្រូវបានបំពេញតែនៅពេលណាដែលមានមូលដ្ឋានច្បាស់លាស់សម្រាប់ការចោទប្រកាន់នេះ ហើយធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា ការចោទប្រកាន់នេះមិនមែនជាការចោទប្រកាន់ដោយស្មានៗនោះឡើយ។ នៅពេលមានមូលហេតុអាចឲ្យជឿជាក់បានថា បុគ្គលណាម្នាក់អាចបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ [...] អាចចាត់វិធានការមួយ ឬច្រើន ក្នុងចំណោមវិធានការនានាដូចមានចែងក្នុងវិធាន ៣៥(២)។

អង្គជំនុំជម្រះពិចារណាឃើញថា ប្រសិនបើសេចក្តីថ្លែងការណ៍ទាំងអស់នេះត្រូវបានរាយការណ៍ដោយត្រឹមត្រូវ សេចក្តីថ្លែងការណ៍នេះមានលក្ខណៈមិនស្របទៅនឹងគោលការណ៍នៃការសន្មតថា គ្មានទោសទេ។ សេចក្តីថ្លែងការណ៍ជាសាធារណៈដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ នួន ជា ដែលសម្តេចនាយករដ្ឋមន្ត្រីបានធ្វើទៅកាន់សារព័ត៌មាន អាចនាំឱ្យមានជំនឿសមហេតុផល និងបំពេញលក្ខខណ្ឌនៃបទដ្ឋាននេះ។ ដោយហេតុថា នាពេលនេះសំណុំរឿងព្រហ្មទណ្ឌដែលមានជនជាប់ចោទ នួន ជា កំពុងរង់ចាំ ការ សម្រេចសេចក្តីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយបើទោះបីជាសេចក្តីថ្លែងការនេះត្រូវបានធ្វើឡើងដោយគ្មានចេតនាអ្វីមួយក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា សេចក្តីថ្លែងការនេះ មានហានិភ័យដែលអាចត្រូវបានគេយកទៅបកស្រាយថា មានការប៉ុនប៉ងដាក់សម្ពាធដោយមិនសមរម្យមកលើចៅក្រមដែលកំពុងទទួលបន្ទុកចាត់ការរឿងក្តីនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា អង្គជំនុំជម្រះអាចចាត់វិធានការណាមួយ ឬមិនចាំបាច់ចាត់វិធានការណ៍មួយក្នុងចំនោមវិធានការនានាដូចមានចែងក្នុងវិធាន ៣៥(២) [...][12]

ការប៉ាន់ស្មានរបស់អង្គជំនុំជម្រះ នៅពេលដែលលក្ខខណ្ឌតម្រូវឱ្យមានគឺ "ចាប់ផ្តើមឡើងដោយ "មូលហេតុអាចជឿជាក់បាន ដែលធ្វើឡើងដោយសក្តានុពលភាពក្នុងការគម្រាមកំហែងដល់រដ្ឋបាលតុលាការអាចបានកើតឡើង [...] [នេះ] *ផ្តល់ការកើនឡើងអំពីការស៊ើបសួរបន្ថែម* និងមិនតម្រូវឱ្យអង្គជំនុំជម្រះចូលរួមក្នុងការពិនិត្យដោយលម្អិតលើអង្គសេចក្តី នៃការចោទប្រកាន់ ឬ ការសង្ស័យនៃការជ្រៀតជ្រែក ឬប៉ាន់ប្រមានបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល"[13]។ ជាការកត់សម្គាល់ អង្គជំនុំជម្រះខកខានមិនបានពន្យល់អំពីអ្វីពិតប្រាកដទៅលើ "ការស៊ើបអង្កេតបន្ថែម" ឬក៏ហេតុផលសម្រាប់ការស៊ើបអង្កេត ដោយសារតែ (១)មេធាវីការពារក្តីមិនអាចបើកការស៊ើបអង្កេតដោយខ្លួនឯងបានដោយអនុលោមតាមវិធាន ៣៥ (២) បរិបទ "មិនច្បាស់លាស់" និងសេចក្តីថ្លែងការណ៍ដែលរងការចោទប្រកាន់ដែល "ពុំមានភាពច្បាស់លាស់"[14]។ ការស៊ើប

---

[12] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៩។ សូមមើលផងដែរកថាខណ្ឌ ៣០ ("សេចក្តីថ្លែងការរបស់នាយករដ្ឋមន្ត្រីបំពេញបទដ្ឋានអប្បបរមាសម្រាប់ការអន្តរាគមពីអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៣៥(២)នៃវិធានផ្ទៃក្នុង។ ហេតុដូចនេះ អនុលោមតាមអនុវិធាននេះដើម្បីផលប្រយោជន៍នៃភាគីទាំងអស់អង្គជំនុំជម្រះសូមបញ្ជាក់ជាថ្មីអំពីគោលការណ៍នៃឯករាជ្យភាពរបស់តុលាការ និងគោលការណ៍នៃការសន្មត់ថា គ្មានទោស ដោយធ្វើការកត់សម្គាល់អំពីសារៈសំខាន់នៃការបំពេញមុខងារដោយត្រឹមត្រូវ និងជំនឿទុកចិត្តលើ អវតក។

[13] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២០ (បញ្ជាក់បន្ថែម)។

[14] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣០។

អង្កេតបែបនេះមិនអាចរាប់បញ្ចូលការពិនិត្យបន្ថែមដោយអង្គជំនុំជម្រះនៃសុចរិតភាពនៃការអះអាងបឋម *(prima facie)* ។ ហើយមិនមានការភ្ញាក់ផ្អើលទាល់តែសោះដែលថា គ្មានសម្អាងផ្នែកច្បាប់ត្រូវបាន លើកឡើងដើម្បីគាំទ្រជំហរនេះ។

៦. អាចនិយាយម្យ៉ាងទៀតថា ពេលដែលទទួលយកលក្ខខណ្ឌបំពេញអប្បបរិមាវិធាន៣៥ និងទទួលស្គាល់ថា បទដ្ឋាននេះ ធ្វើឱ្យចាប់ផ្តើម "ស៊ើបអង្កេតបន្ថែម" ក៏ប៉ុន្តែអង្គជំនុំជម្រះកំណត់ថា "វាជាការពុំចាំបាច់ដែលត្រូវបើកកិច្ចស៊ើបសួរ ដើម្បីបញ្ជាក់ពីយថាភាពនៃសេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់ទាំងនេះឡើយ"[15]។ អង្គជំនុំជម្រះប្រកាន់ជំហរថា ការរំលឹកទូទៅរបស់ខ្លួន នូវសេចក្តីថ្លែងឡើងវិញដែលស្លូតបូត និង គ្មានអំណាច នូវអ្វីដែលមេធាវីការពារគិតថា ជាការគ្មានតម្លៃ ដែលមិនអាចទៅរួច[16] គឺ "គ្រប់គ្រាន់សម្រាប់ពេលនេះ និង [...] [ដែលថា] ពុំចាំបាច់មានវិធានការថែមទៀត"[17]។

៧. ដោយមិនអាចពន្យល់បានសេចក្តីសម្រេចដែលរងការជំទាស់ ភាគច្រើននិយាយច្របូកច្របល់ពីរឿងដែលមិនពាក់ព័ន្ធ។ ខណៈដែលសំណើទទួលស្គាល់ជំហររបស់មេធាវីការពារក្តីថា ការកត់សម្គាល់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បង្កបានជាបទល្មើសព្រហ្មទណ្ឌ មេធាវីការពារក្តីពិតជាយល់ព្រមថា បញ្ហាបែបនេះដែលកំពុងរង់ចាំនៅចំពោះមុខសាលាឧទ្ធរណ៍ប្រទេសកម្ពុជាវា "ជារឿងមួយផ្សេងទេ"[18] គឺចង់និយាយថា បញ្ហា "ទទួលខុសត្រូវខាងព្រហ្មទណ្ឌ"[19] របស់ ហ៊ុន

---

[15] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣១។

[16] សូមមើល សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៧ ("អង្គជំនុំជម្រះសូមបញ្ជាក់ជាថ្មីថា សេចក្តីថ្លែងការទាំងនេះនឹងមិនមានឥទ្ធិពលមកលើអង្គជំនុំជម្រះ ឬចៅក្រមម្នាក់ៗរបស់អង្គជំនុំជម្រះនៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឡើយ។ ដូចដែលអង្គជំនុំជម្រះធ្លាប់បានលើកឡើងម្តងហើយម្តងទៀតថា ចៅក្រមវិជ្ជាជីវៈនៅ អវតក ត្រូវបានសន្មតថា ជាបុគ្គលដែលមានសមត្ថភាពបំពេញមុខងារវិជ្ជាជីវៈរបស់ខ្លួនប្រកបដោយសុចរិតភាព ឯករាជ្យភាព និងមិនលម្អៀង ដោយសំអាងទៅលើការស្បថចូលកាន់តំណែង ការបណ្តុះបណ្តាល និងបទពិសោធន៍។ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងគឺ ជាចៅក្រមដែលមានសមត្ថភាពគ្រប់គ្រាន់ខាងផ្នែកច្បាប់ និងពុំទទួលរងឥទ្ធិពលពីការធ្វើអត្ថាធិប្បាយជាសាធារណៈណាមួយ ដូចសមាជិកនៃស្ថាប័នសាធារណៈដែលអាចមាននោះឡើយ។ អង្គជំនុំជម្រះនឹងពិចារណាតែលើអង្គហេតុ ភស្តុតាង សារណាទាំងអស់ដែលពាក់ព័ន្ធ និងច្បាប់ជាធរមាននៅក្នុងក្របខណ្ឌច្បាប់ដែលខ្លួនមានប៉ុណ្ណោះ ហើយមិនពិចារណាទៅលើមតិសាធារណៈនានាស្តីពីអត្តិភាព ឬនត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់នៅពេលខ្លួនពិភាក្សាចេញសាលក្រមនោះឡើយ"។

[17] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣១។

[18] សំណើ កថាខណ្ឌ ២០។

00815287



សែន គឺមិនមែនជាកម្មវត្ថុនៃសំណើ ដែលតាមពិតសំណើពិតជាសំដៅពិតប្រាកដតែមួយគត់ទៅលើការរំលោភសិទ្ធិមនុស្ស។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានរៀបរាប់ពីមូលហេតុច្រើនណាស់ទៅលើបទដ្ឋានក្នុងការបង្ហាញពីការទទួលខុសត្រូវព្រហ្មទណ្ឌ:

> នៅពេលមានការចោទប្រកាន់អំពីការទួលខុសត្រូវព្រហ្មទណ្ឌ បទដ្ឋានសម្រាប់ការអន្តរាគមន៍ពីអង្គជំនុំជម្រះត្រូវមានកម្រិត។ ត្រង់ប្រការនេះបុគ្គលណាម្នាក់អាចត្រូវបានចាត់ទុកថា ជាអ្នកទទួលខុសត្រូវចំពោះការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ហើយអាចត្រូវបានដាក់ទណ្ឌកម្ម លុះត្រាតែមានភស្តុតាងបង្ហាញថា បុគ្គលនេះបានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ "ដោយដឹង និងដោយចេតនាពិតប្រាកដ" ប៉ុណ្ណោះ។ [...] មិនមានបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌកើតមាននៅក្នុងករណីនេះទេ ដោយអនុលោមតាម [វិធាន ៣៥(១)]។ បើទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានរំលឹកអំពីភាពចាំបាច់ក្នុងការគោរពនិយាមនានាដែលការពារឯករាជ្យភាពរបស់តុលាការ និងគោលការណ៍នៃការសន្និដ្ឋានថាគ្មានទោសដោយអនុលោមតាមវិធាន៣៥(២) នៃវិធានផ្ទៃក្នុង។[20]

> ទាក់ទិននឹងការទទួលខុសត្រូវព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់ ដោយអនុលោមតាមវិធាន ៣៥(១) អង្គជំនុំជម្រះយល់ឃើញថា មិនមានភស្តុតាងក្នុងការបញ្ជាក់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ នៅក្នុងករណីនេះ។ [...] បរិបទនៃការធ្វើសេចក្តីថ្លែងការណ៍ទាំងនេះ ពុំមានទរណាដឹងច្បាស់ឡើយ ហើយសេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់នេះ ក៏មិនមានភាពច្បាស់លាស់ដែរ[21]។

ក៏ប៉ុន្តែមិនមានចំណុចណាក្នុងសំណើ ដែលមេធាវីការពារក្តីបង្ហាញថា បទដ្ឋានខ្ពស់បែបនេះបានបំពេញនោះទេ។ តាមពិតទៅ អំណះអំណាងគឺកំណត់ទៅនឹងការបំពេញទៅនឹងបទដ្ឋាន *បឋមនៃវិធាន ៣៥* ដែលនាំទៅដល់ការស៊ើបអង្កេតបន្ថែមដោយអង្គជំនុំជម្រះ។

៨. អង្គជំនុំជម្រះសម្រេចសន្និដ្ឋានថា សំណើត្រូវបានបដិសេធចោលដោយផ្នែកដោយសារគ្មានអង្គសេចក្តី[22]។

## III. ច្បាប់ពាក់ព័ន្ធ

---

[19] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣០។

[20] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

[21] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៣០។

[22] សេចក្តីសម្រេចដែលរងការជំទាស់ចំណុចចុងក្រោយ ១១។

## ក.ការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ, ការសន្មតទុកជាមុនថាគ្មានទោស និង សំណងដោយសមធម៌ចំពោះការខូចខាតដែលមិនទាក់ទងនឹងប្រាក់កាស

៩. មេធាវីការពារក្តី សូមយោងទៅផ្នែកច្បាប់នៅកថាខណ្ឌទី៨ រហូតដល់ ១៥ នៃសំណើ[23]។ បន្ថែមលើវិធាន៣៥ អង្គជំនុំជម្រះបានសម្រេចដូចខាងក្រោម:

> សមត្ថកិច្ចតុលាការលើរឿងក្តីនៅ អ.វ.ត.ក ត្រូវបានបែងចែកទៅតាមដំណាក់កាលនានានៃរឿងក្តី។ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះមានសមត្ថកិច្ចនៅក្នុងដំណាក់កាលស៊ើបអង្កេត រីឯអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល មានសមត្ថកិច្ចនៅដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបណ្តឹងសាទុក្ខ។ *ប្រសិនបើអនុវត្តឱ្យបានតឹងរឹងចំពោះសំណើយោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ការបែងចែកសមត្ថកិច្ចនេះ អាចនឹងប៉ះពាល់ដល់ការទទួលខុសត្រូវមុខងាររបស់តុលាការ ក្នុងការធានាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌*[24]។

ដូចនេះ ដោយមិនមានមន្ទិលសង្ស័យ អង្គជំនុំជម្រះអាច (និង គួរតែ) អនុវត្តដោយឯករាជ្យដោយអនុលោមតាម "ឆន្ទានុសិទ្ធិទូលាយ" ក្រោមវិធាន៣៥[25] ដើម្បីជាប្រយោជន៍ក្នុងការធានានូវភាពត្រឹមត្រូវនៃនីតិវិធីរបស់ខ្លួន និងសំខាន់នោះដើម្បីបញ្ជាក់ការពិត។ ដូចគ្នានេះដែរនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានធ្វើដូចនេះ អង្គជំនុំជម្រះតុលាការកំពូលអាច (និងគួរតែ) ជួសជុលការខកខានបែបនេះ។

## ខ. ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខប្រឆាំងនឹង

---

[23] សូមមើលឯកសារលេខ E-116/1/1, កថាខណ្ឌ ១៥-១៨។

[24] ឯកសារ E 116/1/6 "សេចក្តីសង្ខេបសំអាងអង្គហេតុនៃចសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ" ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ ERN 00772881–00772887 (សេចក្តីសម្រេចលើភាពត្រឹមត្រូវ) កថាខណ្ឌ ១៤ (បញ្ជាក់បន្ថែម) (ដកស្រង់ឯកសារឯកសារ D314/1/12 "សេចក្តីសម្រេចលើកទីពីរលើបណ្តឹងរបស់ នួន ជា និង អៀង សារីប្រឆាំងនឹងដីការ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី" ថ្ងៃទី ០៩ កញ្ញា ឆ្នាំ ២០១០, ទស្សនដោយឡែករបស់ចៅក្រម Catherine Marchi-Uhel និង Rowan Downing កថាខណ្ឌទី១០ ដល់ ១២)។

[25] សេចក្តីសម្រេចលើត្រឹមត្រូវ កថាខណ្ឌ១៥។

## សេចក្ដីសម្រេចដោយអនុលោមតាមវិធាន ៣៥

១០. ដោយអនុលោមតាមវិធាន ១០៤(៤), "សេចក្ដីសម្រេចលើការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការនៅក្រោមវិធាន ៣៥ (៦)" គឺអាចប្ដឹងសាទុក្ខបាន[26]។ ភាគីមានបំណងប្ដឹងសាទុក្ខលើសេចក្ដីសម្រេចនេះ "ត្រូវដាក់បណ្ដឹងសាទុក្ខភ្លាមៗនេះ ដោយបញ្ជាក់ពីមូលដ្ឋានគាំទ្របណ្ដឹងសាទុក្ខ និងទឡ្ហីករណ៍នានា"[27]។ បណ្ដឹងសាទុក្ខ "ត្រូវបង្ហាញផងដែរអំពីមូលដ្ឋាន ឬខ្លឹមសារនៃសេចក្ដីសម្រេច ដែលខ្លួនជំទាស់ដោយយោងលេខទំព័រ និងវាក្យខណ្ឌជាក់លាក់នៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង"[28]។ "ក្នុងករណីដែលសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បើកឱ្យមានបណ្ដឹងសាទុក្ខភ្លាមៗ ដូចមានចែងក្នុងវិធាន ១០៤(៤)(ក) និង (ឃ) បណ្ដឹងសាទុក្ខត្រូវធ្វើឡើងក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្ដីសម្រេច ឬ ពីថ្ងៃជូនដំណឹងអំពីសេចក្ដីសម្រេចនោះ"[29]។

## គ. បទដ្ឋានទូទៅនៃការពិនិត្យទៅលើបណ្ដឹងសាទុក្ខភ្លាមៗ

១១. "អនុលោមតាម [...] វិធាន ១០៤(១) និង១០៥(២) នៃវិធានផ្ទៃក្នុង បណ្ដឹងសាទុក្ខភ្លាមៗអាចផ្អែកលើទឡ្ហីករណ៍មួយ ឬច្រើនដូចខាងក្រោមៈ កំហុសនៃអង្គហេតុដែលនាំឱ្យសាលក្រមលើអង្គសេចក្ដី ឬសេចក្ដីសម្រេចនោះ មានភាពមិនយុត្តិធម៌ ឬ កំហុសលើអង្គច្បាប់ ដែលនាំឱ្យមោឃៈសាលក្រមលើអង្គសេចក្ដី ឬសេចក្ដីសម្រេចនោះ។ ការភ័ន្តច្រឡំដែលស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គ

---

[26] វិធាន ១០៤(៤) សូមមើលផងដែរវិធាន ៣៥(៦) ("រាល់សេចក្ដីសម្រេចដែលធ្វើឡើងក្រោមវិធាននេះ អាចត្រូវបានប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ឬប្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល តាមករណីសមស្រប។ [...] ចំពោះបណ្ដឹងសាទុក្ខដែលធ្វើឡើងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ម្ចាស់បណ្ដឹងសាទុក្ខត្រូវធ្វើឡើងដោយអនុលោមតាមវិធាន ១០៥(២) និង ១០៧(១)។

[27] វិធាន ១០៥(២)

[28] វិធាន ១០៥(៤) *សម្គាល់* បណ្ដឹងសាទុក្ខភ្លាមៗត្រូវ "ដាក់ជូនក្រឡាបញ្ជីអង្គជំនុំជម្រះ និងត្រូវចុះហត្ថលេខាដោយដើមបណ្ដឹង ឬមេធាវីដើមបណ្ដឹង។ វិធាន ១០៦(២) និង ១០៦(៤) (បញ្ជាក់បន្ថែម)។

[29] វិធាន ១០៧(១)។

ជំនុំជម្រះសាលាដំបូងដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ[30]។ អង្គជំនុំជម្រះបានបញ្ជាក់ថា "ទឡ្ហីករណ៍បណ្តឹងសាទុក្ខដែលមានរៀបរាប់ក្នុងវិធាន ១០៥(២) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងបណ្តឹងសាទុក្ខភ្លាមៗ ត្រូវតែអាន*ដាច់ចេញពីគ្នា*"[31]។ "ក្នុងគោលបំណងទាំងនេះ អ.ជ.ត.ក ខ្លួនឯង អាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី ដើម្បីធ្វើការសម្រេចលើបញ្ហានេះ"[32]។

## IV ទឡ្ហីករណ៍

### ក. បណ្តឹងសាទុក្ខអាចទទួលយកបាន

១២. ដោយសារតែសេចក្តីសម្រេចដែលរងការជំទាស់សម្រេច "លើការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការក្រោមវិធាន ៣៥(៦)"[33] ដូចនេះអាចប្តឹងសាទុក្ខភ្លាមៗបាន។ ជាងនេះទៅទៀតបណ្តឹងសាទុក្ខនេះ (ក) បញ្ជាក់ពី "មូលដ្ឋានគាំទ្របណ្តឹងសាទុក្ខ និងទឡ្ហីករណ៍នានា"[34], (ខ) "បង្ហាញផងដែរអំពីមូលដ្ឋាន ឬខ្លឹមសារនៃសេចក្តីសម្រេច ដែលខ្លួនជំទាស់ដោយយោងលេខទំព័រ និងវាក្យខណ្ឌជាក់លាក់នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង"[35] និង (គ) "ធ្វើឡើងក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេច ឬ ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនោះ"[36]។ អាស្រ័យហេតុនេះហើយបណ្តឹងសាទុក្ខអាចទទួលយកបាន និងដាក់ទាន់ពេលវេលា។

---

[30] ឯកសារ **E-50/2/1/4** "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់" ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ ERN 00702255–00702274 (សេចក្តីសម្រេចដោះលែង) កថាខណ្ឌ ២៧។

[31] សេចក្តីសម្រេចដោះលែង កថាខណ្ឌ ២៨។ ដូចខាងលើ ("ហេតុដូច្នេះដើម្បីសំអាងលើទឡ្ហីករណ៍ទីមួយ ឬ ទីពីរនៃបណ្តឹងសាទុក្ខ (កំហុសឆ្គងនៃអង្គច្បាប់ ឬអង្គហេតុ) ភាគីបណ្តឹងសាទុក្ខមិនតម្រូវបង្ហាញបន្ថែមកំហុសដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលបណ្តាលឲ្យមានផលប៉ះពាល់ដល់សិទ្ធិរបស់ខ្លួនឡើយ")។

[32] វិធាន១០៤(១)។

[33] វិធាន ១០៤(៤)។

[34] វិធាន ១០៥(២)

[35] វិធាន ១០៥(៤)។

[36] វិធាន ១០៧(១)។

00815291



## ខ. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនចាត់វិធានការតាមវិធាន ៣៥ ជាទង្វើដែលមិនអាចការពារបានដោយសារមូលហេតុមួយចំនួន

### *១. អង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងច្បាប់ដោយខកខានមិនបានផ្តល់ការជួសជុលដល់ការរំលោភសិទ្ធិមនុស្សដែលខ្លួនទទួលស្គាល់*

១៣. ដោយទទួលស្គាល់ថា ជាការរំលោភសិទ្ធិមនុស្សយ៉ាងពិតប្រាកដដោយអនុលោមតាមយុត្តិសាស្ត្រអន្តរជាតិ[37] អង្គជំនុំជម្រះខកខានមិន (ដោយគ្មានការពន្យល់) បានចាត់វិធានការតទៅទៀត គឺការផ្តល់ជូននូវការជួសជុលដ៏សមស្របមួយ ដូចដែលមានចែងក្នុងច្បាប់យុត្តិសាស្ត្រដូចគ្នា។ អង្គជំនុំជម្រះមិនរវល់ដល់កាតព្វកិច្ចរបស់ខ្លួន នៅពេលដែលសំណើមានការស្នើសុំយ៉ាងជាក់ច្បាស់សម្រាប់សំណង[38] និងយោងយ៉ាងច្បាស់ទៅលើសំណងដោយសមធម៌ចំពោះការខូចខាតដែលមិនទាក់ទងនិងប្រាក់កាស នៅក្រោមច្បាប់ដែលពាក់ព័ន្ធ[39]។ យោងលើយុត្តិសាស្ត្រអន្តរជាតិដែលដកស្រង់ដោយចៅក្រម លោក នួន ជា គឺចាំបាច់ទទួលបានសំណង (ជាសំណងលុយកាក់ ឬក៏ការបន្ថយទោស)។ និងវាស្ថិតក្នុងសមត្ថភាពតុលាការនេះដើម្បីផ្តល់សំណងដូចនេះ តាមរយៈបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ[40]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះក៏ខកខានមិនបានលើកឡើងសូម្បីតែបញ្ហានេះ ហើយក៏មិនបានគិតដល់ជម្រើសអាចមាន បើទោះជាបានបញ្ជាក់ពីការរំលោភយ៉ាងពិតប្រាកដលើការសន្មតទុកជាមុនថាគ្មានទោស ដែលជាការរំលោភយ៉ាងធ្ងន់ធ្ងរដែលចាំបាច់ត្រូវមានសំណង។ ដោយពិចារណាដល់ច្បាប់ជាធរមាន ការខកខានរបស់អង្គជំនុំជម្រះក្នុងបញ្ហានេះនាំទៅដល់ "កំហុសលើអង្គច្បាប់ដែលធ្វើឲ្យសេចក្តីសម្រេចគ្មានតម្លៃ"[41]។

### *២. អង្គជំនុំជម្រះរំលោភឥទ្ធានុសិទ្ធិរបស់ខ្លួនដោយខកខាន (ក) មិនបានថ្កោលទោស និង ព្រមានលោកនាយករដ្ឋមន្ត្រី និង (ខ) មិនបាន ស៊ើបអង្កេតបន្ថែមទៅលើបរិបទ*

---

[37] សូមមើលសេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៩។

[38] សូមមើលសំណើ កថាខណ្ឌ ២១ ដល់ ២៣។

[39] សូមមើលសំណើ កថាខណ្ឌ ១៥។

[40] សំគាល់ ។

[41]សូមមើលកថាខណ្ឌ ១១ ខាងលើ។

*និងចរិតនៃការកត់សម្គាល់របស់លោក ហ៊ុន សែន*

១៤. ករណីដែលអង្គជំនុំជម្រះ "ដោះស្រាយបញ្ហា[ការកត់សម្គាល់របស់លោក ហ៊ុន សែនភ្លាមៗ][42] តាមពិតប្រសិនបើជាអ្វីដែលសេចក្តីសម្រេចដែលរងការជំទាស់អះអាងថា បានធ្វើនោះ[43] អង្គជំនុំជម្រះត្រូវតែកំណត់ថា មាន"មូលដ្ឋានគ្រប់គ្រាន់"ដើម្បីអនុវត្តតាមវិធាន ៣៥(២)[44] បើទោះជាសេចក្តីសម្រេចដែលរងការជំទាស់ពុំមានលើកអំពីចំណុចនេះក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ សកម្មភាពដែលមានការកំណត់យ៉ាងតឹងរ៉ឹងដោយអង្គជំនុំជម្រះសាលាដំបូង នាំទៅដល់ដំណោះស្រាយមិនមានប្រយោជន៍ ឬក៏មិនមានប្រសិទ្ធភាព ចំពោះការរំលោភសិទ្ធិមនុស្សជាមូលដ្ឋានដែលធានាក្នុងប្រទេសកម្ពុជា។ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការ "ស៊ើបអង្កេតបន្ថែមទៀតដើម្បីបញ្ជាក់ការពិតថាតើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់នាំទៅដល់ការបន្តនីតិវិធី"[45] ជាពិសេសចំពោះការពិពណ៌នារបស់អង្គជំនុំជម្រះថា បរិបទ និងសភាពមិនច្បាស់លាស់[46] បង្ហាញពីកង្វះខាតរបស់តុលាការទៅលើការជ្រៀតជ្រែកជាបន្តបន្ទាប់របស់លោក ហ៊ុន សែន មកលើកិច្ចការ អ.វ.ត.ក។ ករណីទាំងពីរនេះ កង្វះខាតការអនុវត្តសមរម្យរបស់អង្គជំនុំជម្រះសាលាដំបូងនាំទៅដល់ "កំហុសអាចវិនិច្ឆ័យបានក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដែលធ្វើឱ្យប៉ះពាល់ដល់ដើម

---

[42] វិធាន ៣៥(២)(ក)។

[43] សូមមើលសេចក្តីសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌទី៣០ "អាស្រ័យហេតុនេះ អង្គជំនុំជម្រះគាំទ្រដល់ប្រយោជន៍របស់តួអង្គទាំងអស់ គោលការណ៍ឯករាជ្យតុលាការ និងសច្ចធារណ៍នៃនិរទោសដែលគួសបញ្ជាក់ពីសារៈសំខាន់សម្រាប់ដំណើរការត្រឹមត្រូវ និងជំនឿទុកចិត្តដល់ អ.វ.ត.ក។

[44] សូមមើលសេចក្តីសម្រេចអ.ប.ជ នៅកថាខណ្ឌទី ។ កំណត់សម្គាល់: មេធាវីការពារក្តី យល់ឃើញថា "ការបកស្រាយ" បច្ចុប្បន្ន (មិននិយាយដល់ភាពសមហេតុផលនៃការស៊ើបសួរនៅ អ.វ.ត.ក តាមវិធាន ៣៥ "ហេតុផលជឿ "ដើម្បីឈានទៅរកការស៊ើបអង្កេតបន្ថែម" បើសិនជាការស៊ើបអង្កេតនេះ បង្ហាញឬអាចបង្កើត"មូលដ្ឋានគ្រប់គ្រាន់" សម្រាប់ការយកជម្រើសមួយក្នុងចំណោមជម្រើសនានានៅក្រោមវិធាន ៣៥(២) ដែលជាចុងក្រោយអាចលេចចេញនូវភស្តុតាងឱ្យហួសពីវិមតិសង្ស័យ" ដែលឈានទៅរកការដាក់ទណ្ឌកម្ម ។ សូមមើលសេចក្តីសម្រេចខាងលើ នៅកថាខណ្ឌទី [...] ។

[45] វិធាន ៣៥(២)(ខ) ។

[46] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣០។

00815293



បណ្តឹង"[47]។

**ក. អង្គជំនុំជម្រះសាលាដំបូងគួរតែបានចេញការព្រមាន ជាសាធារណៈ ដោយផ្ទាល់ទៅដល់លោកនាយករដ្ឋមន្ត្រី**

១៥. ពេលដែលអង្គជំនុំជម្រះសាលាដំបូងបានរិះគន់យ៉ាងប្រុងប្រយ័ត្នទៅលើការកត់សម្គាល់ ដែលមានបញ្ហា (មិនរួមបញ្ចូលលក្ខខណ្ឌតឹងរ៉ឹង និងដោយអាចគិតបានក្នុងលក្ខណៈប្រសើរបំផុត) [48] អង្គជំនុំជម្រះមិនបានអន្តរាគមន៍ណាមួយតាមវិធាន ៣៥(២) ដូចដែលបានលើកឡើងនោះទេ[49]។ អង្គជំនុំជម្រះ "បញ្ជាក់ជាថ្មី" អំពីសារសំខាន់នៃគោលការណ៍សន្មតទុកជាមុនថាគ្មានទោស។ ទោះបីជាយ៉ាងណាក៏ដោយ បុគ្គលដែលធ្វើសេចក្តីថ្លែងការណ៍ គឺលោក ហ៊ុន សែន មិនដែលត្រូវបានស្តីបន្ទោសចំពោះការប្រព្រឹត្តរួចមកហើយ ឬក៏ទទួលការព្រមានចំពោះការធ្វើសេចក្តីថ្លែងការណ៍មានលក្ខណៈដូចគ្នាបន្តទៀត ដូចដែលបានស្នើសុំ ជាពិសេសដោយមេធាវីការពារក្តីនោះទេ[50]។ តាមពិតទៅ គ្មានវិធានការណាមួយបានធ្វើឡើងនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលគ្មានន័យខ្លឹមសារនោះទេ។

១៦. ការស្តាប់បង្គាប់អំណាចប្រតិបត្តិត្រូវបានមើលឃើញសម្រាប់អ្វីដែល៖ គ្រាន់តែនិយាយដើម្បីបំបាត់ការធានានូវសវនាការត្រឹមត្រូវ ជាការរំលោភដែលកត់មានដោយពុំមានការដាក់ទណ្ឌកម្មនៅក្នុង

---

[47] កថាខណ្ឌ ១១ ខាងលើ ។

[48] នៅ សូមមើលសេចក្តីសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌទី២៥ (ការថ្លែងរបស់ ហ៊ុន សែន) អាច ត្រូវបានគេយល់ថានិយាយសំដៅចំពោះ នួន ជា) ។ ដូចខាងលើនៅកថាខណ្ឌ ២៦ (ការថ្លែងនេះហាក់ដូច ជាផ្ទុះបញ្ចាំង និងអាចត្រូវបានគេមើលឃើញថា នួន ជា មានពិរុទ្ធភាពបើទោះបីជាគាត់មិនទាន់ត្រូវបានគេ បង្ហាញភស្តុតាងតាមច្បាប់នោះ)។ ដូចខាងលើនៅកថាខណ្ឌ ២៦ (បើសិនជាដូច្នេះមែន វាចាត់ទុកជាបុរេវិនិច្ឆ័យទោសនៃសំណុំរឿងព្រហ្មទណ្ឌដែលកំពុងជំនុំជម្រះនៅ អ.វ.ត.ក ដោយមន្ត្រីសាធារណៈជាន់ខ្ពស់ហើយ ហើយវាអាចប៉ះពាល់ទៅលើការយល់ឃើញរបស់សាធារណជនអំពីភាពមានទោសកំហុសរបស់ នួន ជា ។ ដូចខាងលើនៅកថាខណ្ឌ ២៨ (អាស្រ័យហេតុនេះ វាមានហានិភ័យដែលត្រូវបានគេបកស្រាយថាជាការប៉ុនប៉ងការដាក់ឥទ្ធិពលដោយមិនត្រឹមត្រូវមកលើចៅក្រមដែលជំនុំជម្រះករណី ។

[49] សេចក្តីសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌទី៣០ ។

[50] សូមមើលសំណើ នៅកថាខណ្ឌទី ២៤ ។

ប្រទេសនេះ។ ផ្ទុយពីជំហររបស់អង្គជំនុំជម្រះ គឺ*ពុំមានមន្ទិលសង្ស័យ* ទេថា លោក ហ៊ុន សែន និយាយសម្ដីដែលមានបញ្ហា[51]។ ហើយដូចគ្នានេះដែរ គឺ*ពុំមានមន្ទិលសង្ស័យ* ទេថា ពាក្យសំដីដូចនេះគឺសំដៅដោយផ្ទាល់ទៅលើលោក នួន ជា[52]។ ហើយដោយមិនចេញពីភាពតានតឹង ពាក្យសម្ដី *ច្បាស់ណាស់* ឆ្លុះបញ្ចាំងលក្ខណៈដែលលោកនាយករដ្ឋមន្ត្រីគ្រប់គ្រងលើចៅក្រមកម្ពុជា[53]។ ជាអកុសល សេចក្ដីសម្រេចដែលរងការជំទាស់ឆ្លុះបញ្ចាំងកម្រិតដែលមន្ត្រីរបស់គាត់ក្នុងអង្គជំនុំជម្រះសាលាដំបូងតុលាការទាំងនោះ មិនអាចរិះគន់ (និងការដាក់ទណ្ឌកម្ម) ការលើកឡើងដោយខុសច្បាប់នៃអង្គការនីតិប្រតិបត្តិ។ វាមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេថា ចៅក្រមកម្ពុជានៅអវតក តែងតាំងឡើងដោយនយោបាយ[54] ហ៊ានតទល់ជាមួយនឹងមេដឹកនាំផ្ដាច់ការ (ដែលកាន់អំណាចជាង ១០ ០០០ ថ្ងៃ" ដែលបានព្រមានក្នុងពេលថ្មីៗនេះទៅកាន់ការរិះគន់មកលើរូបគាត់ថា "ខ្ញុំមិនគ្រាន់តែធ្វើឱ្យគណបក្សប្រឆាំងខ្សោយប៉ុណ្ណោះទេ តែខ្ញុំនឹងធ្វើឱ្យស្លាប់...ហើយប្រសិនបើអ្នកណាម្នាក់ខ្លាំងហ៊ានធ្វើបាតុកម្ម ខ្ញុំនឹងវ៉ៃឆ្កែទាំងនោះ ហើយចាប់ដាក់ក្នុងទ្រុង"[55]។ ប្រសិនបើការមើលឃើញនេះក្នុងចំណោមបញ្ហាផ្សេងទៀតគួរតែកែតម្រូវសេចក្ដីយល់ខុសរបស់និស្សិតកម្ពុជាចំពោះទស្សនៈដែលចៅក្រមកម្ពុជាត្រូវបានសន្មតថា អាចបំពេញការងាររបស់ខ្លួនដោយសុចរិតឯករាជ្យ និងមិនលម្អៀង[56]។

១៧. វិធានការរឹងប៉ឹង មិនមែនការបញ្ជាក់ "គ្រាន់តែជាទ្រឹស្ដី និងបំភ័ន្ត" គឺចាំបាច់ក្នុងការចាត់វិធានការជាមួយបុគ្គលដូច ហ៊ុន សែន[57]។ ដើម្បីឱ្យមានប្រសិទ្ធភាព វិធានការច្បាប់ត្រូវតែគិតដល់ការពិតនិងការកើនឡើងនៃកម្រិតនៃការគម្រាមកំហែងដែលបានបង្ហាញ។ ប្រសិនបើអង្គជំនុំជម្រះពិតជាជឿថា ការប្រព្រឹត្តខុសរបស់លោកនាយករដ្ឋមន្ត្រី និង ផលប៉ះពាល់ប្រកបដោយល្បិចកលលើករណីលោក នួន ជា នោះគឺជាភារកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការថ្កោលទោសយ៉ាងពិត

---

[51] សូមមើលសំណោះ កថាខណ្ឌ ២, និង ៦។

[52] សូមមើលសំណោះ កថាខណ្ឌ ២។

[53] សូមមើលសំណើ នៅកថាខណ្ឌទី [...] ។

[54] *N.B.* To date, no Cambodian judge has expressed a judicial position at odds with those of the Royal Government of Cambodia.

[55] Brad Adams, *The New York Times*, '10,000 Days of Hun Sen', Op-Ed, 31 May 2012.

[56] សូមមើលសំណើ នៅកថាខណ្ឌទី ២៣, ២៣ ។

[57] សេចក្ដីសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌទី១៥ ។

ប្រាកដទៅលើបុគ្គល មិនមែនពាក្យសម្តីរបស់គាត់ទេ។ តាមពិតទៅ យើងទាំងអស់គ្នាមានចម្ងល់ថា តើលោក ហ៊ុន សែនដែលត្រូវបានជូនដំណឹងអំពីការទិទានដោយស្មានៗរបស់អង្គជំនុំជម្រះសាលាដំបូងដែរឬក៏អត់។ ប្រសិនបើមានការជូនដំណឹងមែននោះ យើងទាំងអស់គ្នាច្បាស់ណាស់ថា គាត់ដេកមិនលក់ ដោយសារតែរឿងនេះ។ គ្រប់កាលៈទេសៈទាំងអស់ វិធានការរបស់អង្គជំនុំជម្រះសាលាដំបូងគឺមិនគ្រប់គ្រាន់ក្នុងការការពារមិនឲ្យមានការរំលោភតទៅទៀត ពីលោកនាយករដ្ឋមន្ត្រី។

## ខ. អង្គជំនុំជម្រះសាលាដំបូងគួរតែបានធ្វើការស៊ើបអង្កេតបន្ថែម

១៨. "លក្ខខណ្ឌបំពេញ"[58] នៃវិធាន ៣៥ ដែលបានរកឃើញការរំលោភ *ជាបឋម* *(Prima facie)* គឺជាភារកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីព្យាយាមកំណត់សភាព និងវិសាលភាពពេញលេញនៃការរំលោភ តាមរយៈការស៊ើបអង្កេតបន្ថែម។ ដោយពិចារណាអំពីភាពមិនច្បាស់លាស់ដែលបានលើកឡើងទាក់ទងនឹងបរិបទនៃការលើកឡើងរបស់លោក ហ៊ុន សែន[59] អង្គជំនុំជម្រះគួរតែបន្តការស៊ើបអង្កេតដោយអនុលោមតាមវិធាន ៣៥(២)(ខ) ដើម្បីកំណត់អំពី "ចេតនាដែលការកត់សម្គាល់ [របស់លោកនាយករដ្ឋមន្ត្រី] ត្រូវបានធ្វើឡើង"[60]។ តែផ្ទុយទៅវិញ បានចាប់ផ្តើមដោយការពិភាក្សាខុសទាក់ទិននឹង "បទដ្ឋានបង្ហាញតម្រូវសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ" (គឺថា បង្ហាញឲ្យលើសពីវិមតិសង្ស័យ) លើកឡើងថា មេធាវីការពារក្តីមិនបានបំពេញបទដ្ឋានខ្ពស់ជាងនេះក្នុងការបង្ហាញពីការទទួលខុសត្រូវព្រហ្មទណ្ឌពិតប្រាកដ[61]។ មេធាវីការពារក្តីបានលើកឡើងនៅក្នុងសំណើដាក់ជូនតុលាការក្រុងភ្នំពេញ (បច្ចុប្បន្ននេះកំពុងខទ្ធរណ៍) នៅក្នុងសំណើនោះក្នុងវិធីណាក៏ដោយបង្ហាញថា គាត់បានប្រព្រឹត្តបទល្មើសយ៉ាងពិតប្រាកដ។ មូលហេតុដែលអង្គជំនុំជម្រះជ្រើសរើសយកវិធីដែលមិនអាចពន្យល់បាន ក៏ប៉ុន្តែហាក់ដូចជាប្រហែលធ្វើឡើងក្នុងគោលបំណងដោះលែងលោកនាយករដ្ឋមន្ត្រីពីការចោទប្រកាន់ធ្ងន់ជាងនេះ តាមរយៈការយល់ដឹងរបស់

---

[58] សេចក្តីសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌទី២៩ ។

[59] សេចក្តីសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ [...] ។

[60] សេចក្តីសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌទី២៩ ។

[61] *N.B.* The Defence did not suggest that the evidence presented demonstrated *conclusively* that Hun Sen had committed criminal activity; nor could it have done so (given its lack of proper investigative authority).

សាធារណៈជន ឬជាងនេះទៅទៀតនោះដើម្បីមានឥទ្ធិពលមិនសមស្របលើនីតិវិធីតុលាការក្រុង។

## *៣. អង្គជំនុំជម្រះមានកំហុសថាសំណើបដិសេធចោលដោយផ្នែក*

១៩. ខណៈដែលអង្គជំនុំជម្រះប្រកាសបដិសេធដោយផ្នែកនៃសំណើ ដោយសារតែការដាក់ជូនជាងដែល ៧[62] ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនមានដប់មួយទំព័រ "បានបញ្ជាក់សំអាងហេតុលម្អិតនៃសេចក្តីសម្រេចដើមរបស់ខ្លួន និង លើកឡើងនូវច្បាប់ជាធរមានទាក់ទិននឹងគោលការណ៍នៃការសន្មតទុកជាមុនថា គ្មានទោសទាក់ទិននឹងសេចក្តីថ្លែងការណ៍របស់មន្ត្រីសាធារណៈ[63]។ បើទោះជាមេធាវីការពារក្តីបានទទួលស្គាល់រួចមកហើយថា កំហុសដូចនេះគឺជាការមិនប៉ះពាល់មួយដែលរហូតមកដល់ពេលនេះអង្គជំនុំជម្រះពិតជាលើកឡើងពីអង្គសេចក្តី នៃសំណើ *ទាំងមូល* ហើយចេញនូវសេចក្តីសម្រេចមានសម្អាងហេតុដែលមានការដកស្រង់ឡើងវិញយ៉ាងវែងអំពីប្រវត្តនីតិវិធីនៃសំណើ[64] (ជាមួយនឹងការចុះចាញ់ជាយថាហេតុ) ជំទាស់នឹងជំហររបស់អង្គជំនុំជម្រះក្នុងការបដិសេធសំណើ។ តាមពិតទៅវាហាក់ដូចជា (តាមពិតវាច្បាស់ណាស់សម្រាប់មេធាវីការពារក្តី)ថា ជំហររបស់អង្គជំនុំជម្រះលើបញ្ហានេះឆ្លុះបញ្ចាំងពីបំណងមិនសំខាន់ដែលអាចដាក់ទណ្ឌកម្មមេធាវីការពារក្តីចំពោះការចចេសរឹងរូសរបស់មេធាវីការពារក្តីក្នុងការលើកឡើងបញ្ហាសំខាន់មួយនេះ បើទោះជា អង្គជំនុំជម្រះមិនពេញចិត្តយ៉ាងពិតប្រាកដក៏ដោយ។ ក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលប្រហែលជានឹងមិនខកខានក្នុងការលើកតម្កើងការខិតខំប្រឹងប្រែងដើម្បីល្បួងលោមដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីដោះស្រាយដោយត្រឹមត្រូវនូវការជំនុំជម្រះដោយយុត្តិធម៌ក្នុងសំណុំរឿង ០០២។

---

[62] សូមមើលសេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៣។ *សម្គាល់* ផ្នែកនៃសំណើត្រូវបានប្រកាសថា "ទទួលយកបានក្នុងប្រភេទជាសំណើដាច់ដោយឡែកមួយដោយអនុលោមតាមវិធាន ៣៥"។ សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៤។

[63] ដូចខាងលើ។

[64] សូមមើលសំណើ កថាខណ្ឌ ២ ដល់ ៧ ។

## គ. អង្គជំនុំជម្រះតុលាការកំពូលត្រូវប្រើឆន្ទានុសិទ្ធិរបស់ខ្លួន និងចាត់ វិធានការបន្ថែមទៀតអនុលោមតាមយុត្តិសាស្ត្រអន្តរជាតិ និងវិធាន ៣៥

២០. សម្រាប់ហេតុផលដែលមានក្នុងសំណើ និងនៅក្នុងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវតែ (១) ផ្តល់នូវសំណងសមស្របចំពោះការរំលោភរបស់ ហ៊ុន សែន មកលើសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌របស់ នួន ជា ដោយអនុលោមតាមយុត្តិសាស្ត្រច្បាប់សិទ្ធិមនុស្សអន្តរជាតិ (២) ដាក់ទណ្ឌកម្មដោយផ្ទាល់ ជាសធារណៈ និងយ៉ាងម៉ឺងម៉ាត់ដល់លោកនាយករដ្ឋមន្ត្រីអនុលោមតាមវិធាន ៣៥(២)(ក) ក្នុងលក្ខណៈដើម្បីការពារមិនឲ្យមានការជ្រៀតជ្រែកបន្តទៅទៀត និង (៣) បង្គាប់ឲ្យមានការស៊ើបអង្កេតអនុលោមតាមវិធាន ៣៥(២)(ខ) ទៅលើសភាព និងបរិបទនៃការកត់សម្គាល់។ តុលាការកំពូលពិតជាមានសិទ្ធិអំណាចធ្វើដូច្នោះ និងដើម្បីសវនាការមួយត្រឹមត្រូវ ចាំបាច់ត្រូវមានវិធានការដូច្នេះ។

## V. សេចក្តីសន្និដ្ឋាន

២១. អាស្រ័យដោយហេតុផលក្នុងបណ្តឹងនេះ តុលាការកំពូលត្រូវតែ (១) ទទួលយកបណ្តឹងនេះ (២) ប្រកាសថា សេចក្តីសម្រេចដែលរងការជំទាស់គឺមិនត្រឹមត្រូវសម្រាប់ហេតុផលដូចបានរៀបរាប់ខាងលើ និង (៣) ចាត់វិធានការបន្ថែមទៀតដូចដែលបានស្នើឡើងដោយមេធាវីការពារក្តីនៅកថាខណ្ឌខាងលើ។ ការផ្តល់អំណះអំណាងក្នុងសវនាការជាសាធារណៈនៅមុនពេលកំណត់ណាមួយលើបណ្តឹងសាទុក្ខនេះ នឹងជាការប្រសើរ ហើយត្រូវបានស្នើក្នុងសំណើនេះ។

**សហមេធាវីការពារក្តីលោក នួន ជា**

Michiel PESTMAN    Jasper PAUW    Andrew IANUZZI